**មាត្រា ៣ :** គណៈកម្មាធិការនេះ មានភារកិច្ចសិក្សាសម្រួលទំនាស់ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការដូចជា ត្រួតពិនិត្យកិច្ចសន្យាទាំងឡាយក្នុងផែនការនៃការបណ្តុះបណ្តាល ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការឡើងឋានន្តរសក្តិ ឬ ការដាក់វិន័យមន្ត្រីរាជការ ការផ្លាស់ប្តូរ ការផ្តល់ប្រាក់បំណាច់ផ្សេង ។ ។ល។

**មាត្រា ៤ :** គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងស្ថាប័នដែលមានការពាក់ព័ន្ធ និង សាមីខ្លួន មកបំភ្លឺក្នុងករណីចាំបាច់ ។

**មាត្រា ៥ :** ការប្រព្រឹត្តិរបស់គណៈកម្មាធិការនេះ អាស្រ័យដោយប្រធានគណៈកម្មាធិការជាអ្នកកំណត់ណែនាំ ។ គណៈកម្មាធិការនេះ មានទីតាំងនៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា ៦ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម អស់លោកក្នុងមាត្រា ២ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៣ អនក្រ.បក**

ស្តីពីការបង្កើតនាយកដ្ឋានបច្ចេកទេស

សេដ្ឋកិច្ច និង ផ្សព្វផ្សាយ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើតនាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ ស្ថិតនៅក្រោមការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២ :** នាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ មានភារកិច្ចសំខាន់ ៗ ដូចតទៅ ÷

- ស្រាវជ្រាវ និង ស្វែងយល់ពីបញ្ហាលំបាក និង តម្រូវការរបស់សហគមន៍ និង កសិករក្នុងកិច្ចអភិវឌ្ឍន៍ ។
- រៀបចកសាងគំរោងកម្មវិធីបំពាក់បំប៉នមុខជំនាញ និងប្រព័ន្ធឃោសនាអប់រំផ្សព្វផ្សាយបច្ចេកទេសលើគ្រប់ផ្នែកក្នុងវិស័យកសិកម្ម ។
- សិក្សាស្រាវជ្រាវរកគំនាស់សេដ្ឋកិច្ចកសិកម្ម និង វិះរកយុទ្ធវិធីផ្សព្វផ្សាយដើម្បីលើកទឹកចិត្តដល់មូលដ្ឋាន និង ប្រជាកសិករឈានទៅអភិវឌ្ឍន៍លើគ្រប់ផ្នែកក្នុងវិស័យកសិកម្ម។
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំឯកសារបច្ចេកទេសកសិកម្មសហការជាមួយអង្គភាពជំនាញនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំអត្ថបទចងក្រងជាទស្សនាវដ្តី ព្រឹត្តិប័ត្រ សាលាកប័ត្រ គំនូររូបភាព រឿងនិទានខ្លី ។ ខ្សែភាពយន្តកាសែ្សត វីដេអូ ។ល។ បំរើអោយការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មលើគ្រប់រូបភាព ។
- កសាងកម្មវិធីបំពាក់បំប៉នដល់ប្រជាកសិករ ដើម្បីលើកកំពស់ការយល់ដឹងខាងបច្ចេកទេសកសិកម្មសមស្របទៅតាមលក្ខណៈភូមិសាស្ត្ររបស់មូលដ្ឋាន ដោយសហការជាមួយអង្គភាពជំនាញនៅមូលដ្ឋាន ក្នុងការធ្វើបង្ហាញ និង ការអនុវត្តន៍ជាក់ស្តែង ។

- រៀបចំការគ្រប់គ្រង និង ប្រើប្រាស់ឥណទានកសិកម្មនៅជនបទដើម្បីជំរុញផលិកម្មកសិកម្មនៅក្នុងសហគមន៍កសិករ ។
- ត្រួតពិនិត្យការអនុវត្តន៍ សន្និដ្ឋានវាយតំលៃអំពីលទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មក្នុងក្របខ័ណ្ឌទូទាំងប្រទេស ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៣ :** នាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និង ផ្សព្វផ្សាយ ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៤ :** ការបង្កើត រំសាយ និង រៀបចំតួនាទីភារៈកិច្ចការិយាល័យរបស់នាយកដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ស្ថាប័នមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារៈកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៦ :** អនុក្រឹត្យនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៥៣ អនក្រ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា